អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦

# សេចក្តីថ្លែងការណ៍
# របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត
# ការបិទការស៊ើបសួរប្រឆាំងនឹង អោ អាន និងការសម្រេចបំបែកសំណុំរឿង ០០៤

នៅថ្ងៃនេះ សហចៅក្រមស៊ើបអង្កេត បានជូនដំណឹងដល់ភាគីទាំងអស់នៅក្នុងសំណុំរឿង ០០៤ និង ០០៤/១ ថាកិច្ចស៊ើប សួរប្រឆាំងនឹង អោ អាន បានបញ្ចប់។ សហចៅក្រមស៊ើបអង្កេត ក៏បានចេញដីកាសម្រេចបំបែកនីតិវិធីពាក់ព័ន្ធនឹង អោ អាន ចេញពីសំណុំរឿង ០០៤ ហើយបង្កើតសំណុំរឿងថ្មី គឺសំណុំរឿង ០០៤/០២។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាសម្រេចដាច់ដោយឡែកមួយ ដោយកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរប្រឆាំងនឹង អោ អាន យោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន*។

សេចក្តីជូនដំណឹងនៅថ្ងៃនេះ គឺជាការបិទកិច្ចស៊ើបសួរដែលបានធ្វើឡើងអស់រយៈពេលជាង ៨ ឆ្នាំ លើ អោ អាន ទាក់ទងនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទថាបានប្រព្រឹត្តឡើងរវាងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ០៦ ខែ មករា ឆ្នាំ ១៩៧៩។ កិច្ចស៊ើបសួរប្រឆាំង អោ អាន បានបើកកិច្ចដំណើរការនីតិវិធីបន្ទាប់ពីទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ ដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨។ បន្ទាប់មក សំណុំរឿង ០០៤ បានពង្រីកវិសាលភាពនៃការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមដែល សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ជាបន្តបន្ទាប់នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១១ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៤ និងថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៥ ហើយចុងក្រោយនៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥។

សហចៅក្រមស៊ើបអង្កេត បានចេញដីកាសម្រេចបំបែកនីតិវិធីពាក់ព័ន្ធនឹង អោ អាន ដោយសារថា ជនត្រូវចោទមានសិទ្ធិទទួលបានសេចក្តីសម្រេចលើបទចោទប្រឆាំងនឹងគាត់ ដោយឥតពន្យារពេលយូរ និង ដើម្បីអាចចេញដីកាដំណោះស្រាយ ក្នុងរយៈពេលមួយសមស្រប អនុលោមតាម វិធាន ៦៧ និង ២១(៤) នៃវិធានផ្ទៃក្នុង ដែលដីកានេះ អាចជាការលើកលែងការចោទប្រកាន់ ឬ ការបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ។ ដោយយល់ឃើញថា កិច្ចស៊ើបសួរលើជនត្រូវចោទម្នាក់ទៀតនៅក្នុងសំណុំរឿង ០០៤ នៅតែបន្តដំណើរការនោះ ទើបយើងយល់ឃើញថា ដើម្បីជាប្រយោជន៍យុត្តិធម៌ គឺត្រូវបំបែកនីតិវិធីពាក់ព័ន្ធនឹង អោ អាន ចេញពីសំណុំរឿង ០០៤។ នីតិវិធីនេះនឹងធ្វើ

ឲ្យសំណុំរឿង អោ អាន ទទួលបាននូវការសម្រេចសេចក្តីអំពីបទចោទប្រឆាំងនឹងគាត់ទាន់ពេលវេលា នៅពេលដែលកិច្ចស៊ើបសួរដែលនៅសេសសល់ទាំងអស់នៅក្នុងសំណុំរឿង ០០៤ នៅតែបន្តដំណើរការ។

***ប្រវត្តិនៃកិច្ចស៊ើបសួរសំណុំរឿង ០០៤***

កិច្ចស៊ើបសួរប្រឆាំងនឹង អ៊ឹម ចែម នៅក្នុងសំណុំរឿង ០០៤ បានបញ្ចប់នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៥ និងបានបំបែកនីតិវិធីនៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៦ ដើម្បីបង្កើតសំណុំរឿង ០០៤/០១ ហើយសហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿងទៅការិយាល័យសហព្រះរាជអាជ្ញានៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០១៦ ហើយសហព្រះរាជអាជ្ញាបានធ្វើសេចក្តីសន្និដ្ឋានស្ថាពរ និង មេធាវីការពារក្តីក៏បានធ្វើការឆ្លើយតបរួចមកហើយ។ បច្ចុប្បន្ននេះ សហចៅក្រមស៊ើបអង្កេត កំពុងតាក់តែងដីកាដំណោះស្រាយ ដែលរំពឹងថានឹងត្រូវចេញនៅក្នុងអំឡុងត្រីមាសទី ១ នៅឆ្នាំ ២០១៧ ខាងមុខនេះ។

កិច្ចស៊ើបសួរប្រឆាំងនឹង យឹម ទិត្យ នៅក្នុងសំណុំរឿង ០០៤ នៅតែបន្តដំណើរការ។ យឹម ទិត្យ ត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដាក់ឲ្យស្ថិតក្រោមការពិនិត្យនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៥។

សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ និងដីកាសម្រេចបំបែកនីតិវិធីពាក់ព័ន្ធនឹង អោ អាន អាចរកបាននៅលើគេហទំព័ររបស់សាលាក្តីខ្មែរក្រហម

https://www.eccc.gov.kh/document/court/39322

https://www.eccc.gov.kh/document/court/39323

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖*


**លោកស្រី ហាយ៉ាត់ អាប៊ូសាឡេស**

មន្ត្រីព័ត៌មានសាធារណៈ

ទូរស័ព្ទចល័តៈ +៨៥៥ (0) ១២ ៤៨៨ ៩៣៦

សារអេឡិចត្រូនិកៈ abusaleh@un.org

**លោក នេត្រ ភក្ត្រា**

មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម

ទូរស័ព្ទចល័តៈ +៨៥៥ (0) ១២ ៤៨៨ ១៥៦

សារអេឡិចត្រូនិកៈ neth.pheaktra@eccc.gov.kh